Kaiser Permanente

# សេចក្តីសង្ខេបអំពីគោលនយោបាយជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ

កម្មវិធីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente (Kaiser Permanente's Medical Financial Assistance, MFA) ផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់អ្នកជំងឺដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលពួកគេទទួលបានក្នុងមន្ទីរពេទ្យ Kaiser Permanente ឬតាមរយៈអ្នកផ្តល់សេវារបស់ Kaiser Permanent។ អ្នកជំងឺអាចដាក់ពាក្យសម្រាប់កម្មវិធី MFA តាមវិធីជាច្រើន ដូចជាជាលក្ខណៈបុគ្គល តាមទូរស័ព្ទ ឬតាមការបំពេញ ឬការដាក់ជូនពាក្យសុំមួយសន្លឹក។ អ្នកជំងឺត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈសម្បត្តិគ្រប់គ្រាន់ខាងក្រោមដើម្បីបំពេញតាមលក្ខណៈសម្បត្តិគ្រប់គ្រាន់។

**តើនរណាអាចទទួលបានសិទ្ធិសម្រាប់ជំនួយហិរញ្ញវត្ថុ និងតើអ្វីជាល័ក្ខខ័ណ្ឌតម្រូវ?**

កម្មវិធីនេះជួយអ្នកជំងឺដែលមានប្រាក់ចំណូលទាប ដែលមិនត្រូវបានធានា ឬដែលទទួលបានសេវាមិនគ្រប់គ្រាន់ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់សម្រាប់ការថែទាំវេជ្ជសាស្ត្រទាំងអស់ ឬមួយផ្នែក។ ជាទូទៅ អ្នកជំងឺអាចមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុ នៅពេលប្រាក់ចំណូលគ្រួសារសរុបនៅត្រឹម ឬក្រោម 350% នៃគោលការណ៍ណែនាំរបស់សហព័ន្ធស្តីពីភាពក្រីក្រ (FPG) ឬមានការចំណាយផ្នែកវេជ្ជសាស្ត្រខ្ពស់ខុសពីធម្មតា។ អ្នកជំងឺគួរតែនិយាយជាមួយទីប្រឹក្សាហិរញ្ញវត្ថុអ្នកជំងឺដើម្បីកំណត់ការទទួលសិទ្ធិ និងសម្រាប់ជួយដាក់ពាក្យសុំ។

*អ្នកជំងឺដែលអាចមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រមិនមានការគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់ដែលបានចេញវិក័យប័ត្រ (AGB) សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងៗទៀត។ សូមមើល* kp.org/mfa/scal *សម្រាប់ព័ត៌មាន AGB។*

**តើ Kaiser Permanente ពិនិត្យអ្នកជំងឺសម្រាប់សិទ្ធិទទួលកម្មវិធីជាសាធារណៈ ឬឯកជនឬទេ?**

Kaiser Permanente ផ្តល់ឲ្យអ្នកជំងឺជាមួយនឹងជំនួយដើម្បីកំណត់កម្មវិធីធានារ៉ាប់រងសុខភាពជាសាធារណៈ ឬឯកជនដែលមានសក្តានុពលដែលអាចជួយបំពេញតម្រូវការនៃការទទួលបានការថែទាំសុខភាព។ អ្នកជំងឺម្នាក់ដែលត្រូវបានសន្មត់សិទ្ធិទទួលបានកម្មវិធីធានារ៉ាប់រងសុខភាពជាសាធារណៈ ឬឯកជនតម្រូវឲ្យដាក់ពាក្យសុំសម្រាប់កម្មវិធីទាំងនេះ។

**តើកម្មវិធីធានាអ្វីខ្លះ?**

កម្មវិធីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រមានការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលបានផ្តល់នៅការិយាល័យវេជ្ជសាស្ត្ររបស់ Kaiser Permanente មន្ទីរពេទ្យ ឱសថស្ថាន ឬបានផ្តល់តាមរយៈអ្នកផ្តល់សេវាថែទាំរបស់ Kaiser Permanente
ប្រភេទនៃសេវាដែលមិនរាប់បញ្ចូល
មានដូចជាសេវាដែលមិនចាត់ទុកជាការសង្គ្រោះបន្ទាន់ ឬភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រតាមរយៈអ្នកផ្តល់សេវាថែទាំរបស់ Kaiser Permanente ការព្យាបាលភាពមិនមានលទ្ធផលបង្កបង្កើត ឬសេវាវះកាត់ និងប្រាក់បុព្វលាភសម្រាប់ការថែទាំសុខភាព។ សូមមើលបញ្ជីព័ត៌មានពេញលេញកាន់តែច្រើនក្នុងគោលនយោបាយ MFA។

**តើមានជំនួយផ្នែកភាសាដែរឬទេ?**

មានអ្នកបកប្រែសម្រាប់អ្នកដោយឥតគិតថ្លៃ។ ពាក្យសុំជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ គោលនយោបាយ និងសេចក្តីសង្ខេបស្តីពីគោលនយោបាយអាចមានជាភាសារបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខ 800-464-4000 ឬចូលមើលវិបសាយរបស់យើងតាម kp.org/mfa/scal។

**តើ Kaiser Permanente មានគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុដែរឬទេ?**

អ្នកអាចស្នើសុំច្បាប់ចម្លងនៃគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ Kaiser Permanente របស់អ្នកតាមរយៈការទូរស័ព្ទទៅ 800-390-3507 ការផ្ញើសំបុត្រតាមប៉ុស្តិ៍ប្រៃសណីយ៍ P.O. Box 7086, Pasadena, CA 91109-7086, ឬចូលមើលវិបសាយរបស់យើងតាម kp.org/mfa/scal។

**តើត្រូវការជំនួយឬទេ?**

សម្រាប់ជំនួយ ឬសំណួរអំពីដំណើរការដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ សូមទូរស័ព្ទទៅ 800-390-3507 ឬនិយាយជាមួយទីប្រឹក្សាហិរញ្ញវត្ថុនៅក្នុងផ្នែកអនុញ្ញាតចូលពេទ្យនៅមន្ទីរពេទ្យ Kaiser Permanente។

©2015 Kaiser Foundation Hospital;
Kaiser Foundation Health Plan, Inc.

**តើខ្ញុំដាក់ពាក្យសុំដោយរបៀបណា?**

អ្នកអាចដាក់ពាក្យសុំសម្រាប់ជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រតាមវិធីជាច្រើន -- តាមរយៈការស្នើសុំព័ត៌ស្តីពីកម្មវិធីជាលក្ខណៈបុគ្គល ឬការស្នើសុំពាក្យសុំពីប្រភពដូចខាងក្រោម៖

- ទីប្រឹក្សាហិរញ្ញវត្ថុនៅក្នុងផ្នែកអនុញ្ញាតចូលពេទ្យ ឬសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ Kaiser Permanente
- សូមទូរស័ព្ទទៅ 800-390-3507
- តាមរយៈការផ្ញើសំបុត្រ (ដោយឥតគិតថ្លៃ) តាមប៉ុស្តិ៍ប្រៃសណីយ៍ P.O. Box 7086, Pasadena, CA 91109-7086
- ទាញយកពាក្យសុំតាមរយៈវិបសាយសហគមន៍របស់ Kaiser Permanente តាម kp.org/mfa/scal។

សូមប្រគល់ពាក្យសុំដែលបំពេញរួច ( ដូចជារាល់ឯកសារ និងព័ត៌មានដែលតម្រូវដែលបានកំណត់ក្នុងសេចក្តីណែនាំស្តីពីការដាក់ពាក្យសុំ ) ទៅផ្នែកចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ឬសង្គ្រោះបន្ទាន់របស់មន្ទីពេទ្យ Kaiser Permanente ដែលជិតបំផុត ឬផ្ញើពាក្យសុំទៅ៖ កម្មវិធី MFA និងតាមប៉ុស្តិ៍ប្រៃសណីយ៍ P.O. Box 7086, Pasadena, CA 91109-7086.

Kaiser Permanente នឹងពិនិត្យពាក្យសុំដែលដាក់ជូន នៅពេលឯកសារទាំងនេះបំពេញរួចរាល់ ហើយនឹងកំណត់ថាតើអ្នកអាចមានសិទ្ធិទទួលជំនួយដោយស្របតាមគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente ឬទេ។ ពាក្យសុំដែលបានមិនបានបំពេញរួច អាចបណ្តាលឲ្យមានការពន្យារពេលក្នុងដំណើរការ ឬការបដិសេធពាក្យសុំ MFA របស់អ្នក ប៉ុន្តែ Kaiser Permanente នឹងជូនដំណឹងដល់អ្នកដាក់ពាក្យសុំ និងផ្តល់ឱកាសក្នុងការផ្ញើឯកសារ ឬព័ត៌មានដែលបាត់តាមការផុតកំណត់ដែលតម្រូវ។

©2018 Kaiser Foundation Hospital;
Kaiser Foundation Health Plan, Inc.